ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01 / 03 / 2013
ម៉ោង (Time/Heure) : 13:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/171

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ច័ន្ទ ទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

## សវនាការពិភាក្សាលើផលវិបាកកើតចេញពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៥៨

រៀបចំដោយ: ដាវ អានសាន និង Roger PHILLIPS

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក ឌុច ផារី, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជា លាង, លោក ANDREW Carley, កញ្ញា សុង ឆវ័ន្ត, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael G. Karnavas |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី ទី ស្រ៊ីនណា, លោកស្រី Christine MARTINAU, លោកស្រី ស៊ីន សុវ៉ន, លោក ហុង គឹមសួន, លោកស្រី Lima NGUYEN, លោកស្រី Beini YE , លោក វ៉ែន ពៅ, លោក គឹម ម៉េងឃី |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ គ្មាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោកស្រី Susan LAMB, លោក Simon MEISENBERG, កញ្ញា Elburg VAN BOETZELAER |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.១០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៤៥ | បញ្ចប់ម៉ោង៖ ១៣.៤៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ១០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការតែងតាំងចៅក្រមជំនួស (ចៅក្រម Fenz ជំនួសចៅក្រម Cartwright) | អង្គជំនុំជម្រះ | ០៩.១១ | ០៩.១៤ |
| ការសម្រេចលើសំណើចូលរួមសវនាការពីចម្ងាយពីសំណាក់ជនជាប់ចោទ អៀង សារី និងខៀវ សំផន | អង្គជំនុំជម្រះ | ០៩.១៤ | ០៩.១៥ |
| សំណើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសវនាការដោយ នួន ជា | នួន ជា | ០៩.១៤ | ០៩.១៥ |
| សំណើពិគ្រោះជាមួយកូនក្តី មុននឹងធ្វើសំណើដោយក្រុមមេធាវីការពារក្តី | ក្រុមមេធាវី នួន ជា | ០៩.១៥<br>១៤.៤៥ | ០៩.១៦<br>១៤.៤៦ |

| | | | |
|---|---|---|---|
| | ក្រុមមេធាវី ខៀវ សំផន | ០៩.១៦<br>១៤.៤៨ | ០៩.១៩<br>១៤.៤៩ |
| | ក្រុមមេធាវី អៀង សារី | ០៩.៤៤<br>១៤.៤៦ | ០៩.៤៦<br>១៤.៤៨ |
| ការរំលឹកអំពីនីតិវិធីដែលពាក់ព័ន្ធ, ការកំណត់កាលបរិច្ឆេទសវនាការ និងការណែនាំអំពីកិច្ចពិភាក្សាដេញដោលលើកិច្ចបំបែកនីតិវិធី | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ០៩.១៩<br>០៩.៣៦<br>១០.២០ | ០៩.៣៥<br>០៩.៥៥<br>១០.៣០ |
| សំណើរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ០៩.៥៦<br>១០.៥១<br>១៤.២១<br>១៥.១៥ | ១០.៣១<br>១១.៤៧<br>១៤.៤២ |
| សេចក្ដីបញ្ជាក់អំពីការចេញសាលក្រម | អង្គជំនុំជម្រះ | ១១.០២ | ១១.០៤ |
| សំណើលះបង់សិទ្ធិតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវី អៀង សារី<br>អង្គជំនុំជម្រះ | ១៣.៤៤ | ១៣.៤៨ |
| ការពិភាក្សាអំពីការកំណត់កាលបរិច្ឆេទស្ដាប់សក្ខីកម្មសាក្សី TCW-665 និង TCW-673 | មេធាវី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>មេធាវី នួន ជា<br>មេធាវី អៀង សារី | ១៣.៥០<br>១៦.០១ | ១៤.២១<br>១៦.០៤ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការតែងតាំងចៅក្រមជំនួស**

ប្រធានអង្គជំនុំជម្រះប្រកាសតែងតាំងចៅក្រម Claudia FENZ ជំនួសចៅក្រម Silvia CARTWRIGHT ដែលអវត្តមានពីសវនាការដោយមានធុរៈផ្ទាល់ខ្លួន។

**ការសម្រេចលើសំណើចូលរួមសវនាការពីចម្ងាយពីសំណាក់ជនជាប់ចោទ អៀង សារី និងខៀវ សំផន**

អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី និងខៀវ សំផន មានវត្តមាន និងតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ សម្រាប់សវនាការពេញមួយថ្ងៃ ដោយសារជនជាប់ចោទទាំងពីររូបមានបញ្ហាសុខភាព។

**សំណើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងសវនាការរបស់ នួន ជា**

ជនជាប់ចោទ នួន ជា បានលះបង់សិទ្ធិមានវត្តមាននៅក្នុងសវនាការ ខណៈពេលជនជាប់ចោទរូបនេះ បានចូលសម្រាកនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**សំណើពិគ្រោះជាមួយកូនក្តី មុននឹងធ្វើសំណើដោយក្រុមមេធាវីការពារក្តី**

ក្រុមមេធាវី នួន ជា ខៀវ សំផន និង អៀង សារី បានបញ្ជាក់ថា ក្រុមខ្លួននឹងធ្វើសេចក្តីសន្និដ្ឋានណាមួយបានពាក់ព័ន្ធនឹងសវនាការពិភាក្សានេះ ក្រោយពីបានពិភាក្សាជាមួយកូនក្តីរបស់ខ្លួន។ ក្រុមមេធាវីការពារក្តីនឹងធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅថ្ងៃ ពុធ ។

**ការរំលឹកអំពីនីតិវិធីដែលពាក់ព័ន្ធ, ការកំណត់កាលបរិច្ឆេទសវនាការ និងការណែនាំអំពីកិច្ចពិភាក្សាដេញដោលលើកិច្ចបំបែកនីតិវិធី**

ប្រធានអង្គជំនុំជម្រះរំលឹកឡើងវិញអំពីកិច្ចនីតិវិធី សំណើសុំ និងសេចក្តីសម្រេចកន្លងមក ដែលពាក់ព័ន្ធដល់កិច្ចបំបែកដំណើរការនីតិវិធី និងវិសាលភាពនៃសំណុំរឿង ០០២/០១។

ដោយប្រឈមនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ នួន ជា និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធនឹងកិច្ចបំបែកនីតិវិធីនៃសំណុំរឿង ០០២ អង្គជំនុំជម្រះនឹងកំណត់កាលបរិច្ឆេទឡើងវិញ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សី និងអ្នកជំនាញជាបន្តបន្ទាប់។

អង្គជំនុំជម្រះស្នើឲ្យភាគីទាំងអស់ឆ្លើយតបនឹងអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី ១២ កុម្ភៈ ២០១៣ ដែលផ្តោតទៅលើសំណួរចំនួន ៩។ សហព្រះរាជអាជ្ញាស្នើឆ្លើយតបគ្រប់សំណួរក្នុងពេលតែម្តង ប៉ុន្តែ អជសដ បង្គាប់ឲ្យភាគីធ្វើការឆ្លើយតបមួយសំណួរម្តងៗ ដើម្បីផ្តល់ភាពងាយស្រួលដល់ការចេញសេចក្តីសម្រេច។

**សំណើរបស់សហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យកិច្ចពិភាក្សាដេញដោលគប្បីធ្វើទៅលើរាល់សំណួរទាំងអស់តែម្តង

ដោយសារសំណួរទាំង ៩ របស់ អជសដ (ឯកសារ E163/5/1/13/1) ទាំងនេះពាក់ព័ន្ធគ្នា។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គាំទ្រសំណើនេះ។ មេធាវី អៀង សារី មិនគាំទ្រ។ អជសដ សម្រេចថា ភាគីនឹងត្រូវឆ្លើយម្តងមួយសំណួរៗ តាមអនុស្សរណៈរបស់ អជសដ។

**<u>សេចក្តីបញ្ជាក់ដោយអង្គជំនុំជម្រះអំពីការចេញសាលក្រម សំណុំរឿង ០០២/០១</u>**

ចៅក្រម Fenz បានបញ្ជាក់ដល់ភាគី និងសាធារណជនថា អជសដ ត្រូវការពេលវេលាច្រើនថែមទៀត បន្ទាប់ពីការបញ្ចប់សវនាការលើភស្តុតាង ក្នុងការព្រាងសាលក្រម ដោយសារតែមានបញ្ហាប្រឈមជាច្រើនផ្នែកភស្តុតាង និងផ្លូវច្បាប់ ពាក់ព័ន្ធនឹងសំណុំរឿង ០០២។

**<u>សំណើលះបង់សិទ្ធិតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

ដោយសារមូលហេតុសុខភាពមិនអនុគ្រោះ ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិ និងមិនចូលរួមសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការសម្រាប់សវនាការវេលារសៀល និងសវនាការនៅថ្ងៃបន្ទាប់។

**<u>ការពិភាក្សាអំពីការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មសាក្សី TCW-665 និង TCW-673</u>**

ក្រុមមេធាវីការពារក្តី ខៀវ សំផន បានស្នើកំណត់កាលបរិច្ឆេទឡើងវិញនូវសវនាការស្តាប់សក្ខីកម្មសាក្សីអត្តចរិត ដែលមានរហស្សនាម TCW-665 និង TCW-673 រហូតទាល់តែវិសាលភាពនៃសំណុំរឿង ០០២ ត្រូវបានកំណត់ច្បាស់លាស់ ដោយសារសាក្សីទាំងនេះទាក់ទងមិនត្រឹមតែអត្តចរិករបស់ជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែអាចទាក់ទងនឹងការចោទប្រកាន់លើអង្គហេតុផ្សេងទៀត។ អជសដ បានសម្រេចលើកពេលស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះ។

<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>

| លេខ អជសដ | លេខ កសចស | ចំណងជើង | ភាគី | សម្គាល់ (លេខ ERN) |
|---|---|---|---|---|

<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>

- អនុញ្ញាតឱ្យជនជាប់ចោទ ខៀវ សំផន និងអៀង សារី ចូលរួមសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អវតក

វិញ និងអាចអវត្តមាននៅក្នុងសវនាការវេលារសៀល និងសវនាការនៅថ្ងៃបន្ទាប់។

- សម្រេចលើកពេលស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម TCW-665 និង TCW-673។
- បង្គាប់ឱ្យនាំជនជាប់ចោទ ខៀវ សំផន មកកាន់សាលសវនាការឱ្យបានមុនម៉ោង ០៩.00 ព្រឹក នៅថ្ងៃ ពុធ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ដាវ ឆាន់សាន** Roger PHILLIPS